**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**សម្ដេចព្រះមហាក្សត្រ នរោត្តម សីហមុនី ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈ**

ក្នុងឱកាសដ៏នក្ខត្តប្ញក្ស នៃទិវាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ **មមែ** សប្តស័ក ព.ស ២៥៥៩ គ.ស ២០១៥ នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូមសម្ដែងនូវកតញ្ញូកតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតថ្វាយ **សម្ដេចព្រះមហាក្សត្រ** ជាទីគោរពសក្ការៈ ដែលទ្រង់ប្រោសព្រះរាជទានព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ ដើម្បីក្នុងនាមមនុស្សធម៌ជួយដល់ប្រជានុរាស្ត្រទីទ័លក្រ និងប្រជានុរាស្ត្ររងគ្រោះដោយសារគ្រោះធម្មជាតិផ្សេងៗ។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំអោនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកមានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃព្រះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទាននូវព្រះស័ព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរថ្វាយចំពោះ **សម្ដេច ព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយ ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ក្សេមក្សាន្ត នៃទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា និងប្រជាពលរដ្ឋកម្ពុជា ជាកូន ជាចៅ ចៅទួត របស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្ដេចព្រះមហាក្សត្រ** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**